# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលហុងគ្រី

## ស្តីពី
## ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលហុងគ្រី (ចាប់ពីពេលនេះតទៅហៅថា ភាគីជាប់កិច្ចសន្យា)

ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងភាគីទាំងពីរ លើមូលដ្ឋានស្មើភាព និងមានផលប្រយោជន៍ទៅវិញទៅមក

ដោយមានចេតនាបង្កើត និងរក្សាបាននូវលក្ខខណ្ឌអំណោយផលសម្រាប់ការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងនៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និង

ដោយទទួលស្គាល់ថា ការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគដែលអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ នឹងជំរុញឱ្យមានគំនិតផ្តួចផ្តើមធុរកិច្ច នៅក្នុងវិស័យនេះបានព្រមព្រៀងគ្នាដូចតទៅ :

### មាត្រា ១
### និយមន័យ

នៅក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ

១- ពាក្យ "វិនិយោគ" ត្រូវរាប់បញ្ចូលទ្រព្យសម្បត្តិគ្រប់ប្រភេទ ដែលបានវិនិយោគទាក់ទងទៅនឹងសកម្មភាពសេដ្ឋកិច្ច ធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យា

ម្ខាងនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីម្ចាស់ផ្ទះ និងដែលរួមបញ្ចូលជាពិសេសមានជាអាទិ៍ តែពុំកំណត់ត្រឹមអ្វីដូចមានរៀបរាប់ខាងក្រោមនេះឡើយ ៖

ក- ចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត ដូចជា ហ៊ីប៉ូតែក សិទ្ធិឃាត់ទុកទ្រព្យរបស់កូនបំណុល សិទ្ធិលើការ និងសិទ្ធិប្រហាក់ប្រហែលដទៃទៀត

ខ- ភាគហ៊ុន ហ៊ុន និងប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬការរួមចំណែកក្នុងក្រុមហ៊ុនតាមទម្រង់ផ្សេងៗទៀត

គ- សិទ្ធិលើបំណុលដែលមានបំណងឱ្យសងជាប្រាក់ ឬសិទ្ធិទាមទារឱ្យបំពេញកាតព្វកិច្ចណាមួយដែលមានតម្លៃសេដ្ឋកិច្ចពាក់ព័ន្ធទៅនឹងការវិនិយោគ

ឃ- កម្មសិទ្ធិបញ្ញា និងសិទ្ធិឧស្សាហកម្ម រួមបញ្ចូល សិទ្ធិអ្នកនិពន្ធ ពាណិជ្ជសញ្ញា ប្រកាសនីយប័ត្រតក្កកម្ម គំនូរ សិទ្ធិនៃអ្នកបង្កាត់ពូជ ការកែច្នៃបច្ចេកទេស ជំនាញវិជ្ជាជីវៈ ការសម្ងាត់ផ្នែកពាណិជ្ជកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រ ពាណិជ្ជនាម និងកិត្តិនាមជំនួញភ្ជាប់ជាមួយទៅនឹងការវិនិយោគ

ង- សិទ្ធិផ្សេងទៀតដែលកើតឡើងដោយច្បាប់ ឬចែងដោយកិច្ចសន្យា ឬអាជ្ញាប័ណ្ណណាមួយ និងការអនុញ្ញាតដោយអនុលោមទៅតាមច្បាប់ រួមបញ្ចូលសម្បទាន ក្នុងការរុករក ការធ្វើនិស្សារណកម្ម ការដាំដុះ ឬការធ្វើអាជីវកម្មធនធានធម្មជាតិ ។

ការផ្លាស់ប្តូរណាមួយនៃទ្រង់ទ្រាយរបស់ទ្រព្យសម្បត្តិ ដែលបានវិនិយោគ មិនមានឥទ្ធិពលទៅលើចរិតលក្ខណៈនៃការវិនិយោគនោះឡើយក្នុងលក្ខខណ្ឌថា ការផ្លាស់ប្តូរនេះ ត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា នៅក្នុងទឹកដីដែលការវិនិយោគ ត្រូវបានធ្វើ។

២- ពាក្យ "អ្នកវិនិយោគ" សំដៅដល់រូបវ័ន្ត ឬនីតិបុគ្គលនៃភាគីជាប់សន្យាម្ខាងដែលបានធ្វើការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

ក- ពាក្យ "រូបវ័ន្តបុគ្គល" សំដៅដល់បុគ្គល ដែលមានសញ្ជាតិរបស់ភាគីជាប់កិច្ចសន្យាណាមួយ ស្របទៅតាមច្បាប់របស់ភាគីនោះ

ខ- ពាក្យ "នីតិបុគ្គល" ចំពោះភាគីជាប់កិច្ចសន្យាណាមួយសំដៅដល់នីតិបុគ្គលណាមួយដែលបានចុះបញ្ជី ឬបង្កើតឡើងស្របទៅតាមច្បាប់របស់ខ្លួនដែលមានស្នាក់ការកណ្តាល ឬទីតាំងកណ្តាលនៃធុរកិច្ចស្ថិតនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាង។ សម្រាប់ករណីហុងគ្រី ពាក្យនេះក៏មានរួមបញ្ចូលនូវៈ ក្រុមហ៊ុនទូទៅ (kkt) និង ក្រុមហ៊ុនមានកំរិត (bt) ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនឯកបុគ្គល (ec/kfc) ។

៣- ពាក្យ "ទិន្នផល" សំដៅដល់ផលដែលទទួលបានពីការវិនិយោគមួយ និងជាពិសេសរួមបញ្ចូលមានជាអាទិ៍ ប្រាក់ចំណេញ ការប្រាក់ ចំណូលមូលធន ភាគលាភ កម្រៃ ឬថ្លៃឈ្នួលផ្សេងៗ ។

៤- ពាក្យថា "ទឹកដី" សំដៅដល់ៈ

ក- ចំពោះព្រះរាជាណាចក្រកម្ពុជា គឺដែនដី ដែនសមុទ្រ បាតសមុទ្រ និងស្រទាប់ក្រោមដី និងដែនអាកាសដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិគ្រប់គ្រងអធិបតេយ្យភាព ឬអនុវត្តយុត្តាធិការស្របទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ

ខ- ចំពោះហុងគ្រី គឺទឹកដីដែលហុងគ្រី មានសិទ្ធិគ្រប់គ្រង អធិបតេយ្យភាព សិទ្ធិត្រួតត្រា ឬយុត្តាធិការស្របតាមច្បាប់អន្តរជាតិ។

៥- ពាក្យថា "រូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី" សំដៅដល់រូបិយប័ណ្ណដែលត្រូវប្រើប្រាស់ជាទូទៅ សម្រាប់ទូទាត់ក្នុងកិច្ចការជំនួញអន្តរជាតិ ហើយដែលត្រូវផ្លាស់ប្តូរជាទូទៅនៅទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ ការប្រើប្រាស់រូបិយប័ណ្ណមិនផ្ទុយទៅនឹងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យាម្ខាង និងឯរាជ្យភាព ក្នុងក្របខណ្ឌអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលអាចផ្ទេរ ឬប្តូរបានដោយសេរី។

## មាត្រា ២
## ការជំរុញ និងការការពារវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវលើកទឹកចិត្ត និងបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគនៅក្នុងទឹកដីរបស់ខ្លួន និងត្រូវទទួលស្គាល់ការវិនិយោគនេះស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

២- ការវិនិយោគ និងទិន្នផល នៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងត្រូវទទួលបានគ្រប់ពេលវេលានូវប្រព្រឹត្តិកម្មដោយត្រឹមត្រូវ និងសមធម៌ ព្រមទាំងត្រូវទទួលបាននូវការការពារ និងសន្តិសុខពេញលេញនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៣- ភាគីជាប់កិច្ចសន្យា ពុំត្រូវជំរុញលើកទឹកចិត្តការវិនិយោគដែលនាំដល់ការបន្ធូរបន្ថយការអនុវត្តច្បាប់ស្តីពីបរិស្ថានក្នុងស្រុក ច្បាប់ការងារ ឬច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារ ឬដោយមិនចាប់អារម្មណ៍ដល់ចំណុចសំខាន់នៃស្តង់ដារការងារឡើយ។ នៅពេលណាដែលភាគីជាប់កិច្ចសន្យាម្ខាង យល់ឃើញថាភាគីជាប់កិច្ចសន្យាម្ខាងទៀតបានផ្តល់នូវការលើកទឹកចិត្តបែបនេះ ភាគីនោះអាចលើកសំណើសុំឱ្យមានការពិគ្រោះយោបល់ជាមួយភាគីម្ខាងទៀត ហើយភាគីទាំងពីរត្រូវធ្វើការពិគ្រោះគ្នាក្នុងទស្សនៈដើម្បីបញ្ចៀសឱ្យបាននូវការលើកទឹកចិត្តណាមួយដូចខាងលើនេះ។

## មាត្រា ៣
## ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវអនុញ្ញាតឱ្យការវិនិយោគ និងទិន្នផលនៃការវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួន ទទួលបាននូវប្រព្រឹត្តិកម្មដោយត្រឹមត្រូវ និងសមធម៌ និងមានភាពអនុគ្រោះមិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមផ្តល់ឱ្យសម្រាប់ការវិនិយោគ និងទិន្នផលវិនិយោគនៃអ្នកវិនិយោគរបស់ខ្លួន ឬការវិនិយោគ និងទិន្នផលវិនិយោគរបស់តតីយរដ្ឋនោះឡើយ ពោលគឺត្រូវផ្តល់ឱ្យនូវប្រព្រឹត្តិកម្មណាមួយដែលមានភាពអនុគ្រោះជាងគេ ។

២- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវអនុញ្ញាតឱ្យអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួន ទាក់ទងនឹងការគ្រប់គ្រង ការថែទាំ ការប្រើប្រាស់ ការទទួលបាន ឬការចាត់ចែង ការវិនិយោគរបស់គេ នូវប្រព្រឹត្តិកម្មត្រឹមត្រូវ និងសមធម៌ និងមានភាពអនុគ្រោះមិនតិចជាងអ្វីដែលបានផ្តល់ឱ្យចំពោះអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃតតីយរដ្ឋនោះឡើយពោលគឺ ត្រូវផ្តល់ឱ្យនូវប្រព្រឹត្តិកម្មណាមួយដែលមានភាពអនុគ្រោះជាងគេ ។

៣- បញ្ញត្តិស្តីពីប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត នៃកិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះផលប្រយោជន៍ ដែលភាគីជាប់កិច្ចសន្យា មួយបានទទួលដោយអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួន ដែលជាសមាជិក នៃ សហគមន៍គយ សេដ្ឋកិច្ច ឬរូបិយវត្ថុ ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនោះទេ ។

៤- ភាគីជាប់កិច្ចសន្យាយោគយល់ពីកាតព្វកិច្ចនៃភាគីជាប់កិច្ចសន្យាមួយ ដែលជាសមាជិក នៃសហគមន៍គយ សេដ្ឋកិច្ច ឬរូបិយវត្ថុ ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរី រួមបញ្ចូលទាំងកាតព្វកិច្ចដែលកើតចេញពីកិច្ចព្រមព្រៀងអន្តរជាតិ ឬការសម្របសម្រួលទៅវិញទៅមកនៃសមាគមន៍គយ សេដ្ឋកិច្ច ឬរូបិយវត្ថុ ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនោះ។

៥- បញ្ញត្តិនៃមាត្រានេះពុំត្រូវបានចាត់ទុកថា ជាការបង្ខំឱ្យភាគីជាប់កិច្ចសន្យាមួយធ្វើការបើកទូលាយឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ឬការវិនិយោគ ឬទិន្នផលនៃការវិនិយោគរបស់អ្នកវិនិយោគនោះទទួលបាន នូវផលប្រយោជន៍ពីប្រព្រឹត្តិកម្ម បុព្វសិទ្ធ ឬភាពអនុគ្រោះ ដែលភាគីម្ចាស់ផ្ទះអាចទទួលបានដោយផ្អែកលើ :

- ក- ទម្រង់នៃកិច្ចព្រមព្រៀងពហុភាគីណាមួយស្តីពីការវិនិយោគដែលភាគីជាប់កិច្ចសន្យាណាមួយជា ឬអាចនឹងក្លាយទៅជាសមាជិក
- ខ- កិច្ចព្រមព្រៀង ឬការសម្របសម្រួលជាអន្តរជាតិណាមួយពាក់ព័ន្ធទាំងស្រុង ឬជាពិសេសទៅនឹងកិច្ចការពន្ធដារនោះឡើយ។

## មាត្រា ៤
## អស្សាមិករណ៍

ការវិនិយោគ ឬទិន្នផលនៃការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាណាមួយមិនត្រូវបានធ្វើជាតូបនីយកម្មដកហូត ឬទទួលរងនូវវិធានការ ដែលមានឥទ្ធិពលស្មើនឹងជាតូបនីយកម្ម ឬដកហូត (ចាប់ពីពេលនេះតទៅហៅថា អស្សាមិករណ៍) នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ លើកលែងតែដើម្បីផលប្រយោជន៍សាធារណៈ។ អស្សាមិករណ៍ត្រូវដំណើរការអនុវត្តតាមនីតិវិធីនៃច្បាប់ លើមូលដ្ឋានគ្មានការរើសអើង និងត្រូវភ្ជាប់ជាមួយនូវបញ្ញត្តិស្ដីពី ការទូទាត់សំណងភ្លាមៗឱ្យបានគ្រប់គ្រាន់ និងមានប្រសិទ្ធិភាព។ សំណងដូចនេះត្រូវមានទឹកប្រាក់ស្មើនឹងតំលៃទីផ្សារនៃការវិនិយោគដែលត្រូវបានដកហូត នៅពេលភ្លាមៗមុនពេល ធ្វើអស្សាមិករណ៍ ឬនៅមុនពេលដែលអស្សាមិករណ៍នោះត្រូវបានដឹងជាសាធារណៈ (មួយណាដែលឆាប់ជាង) ដោយត្រូវបូកបញ្ចូលនូវការប្រាក់តាមអត្រាពាណិជ្ជកម្មសមស្រប និងចាប់គិតពីថ្ងៃធ្វើអស្សាមិករណ៍រហូតដល់ថ្ងៃដែលត្រូវទូទាត់ជាក់ស្ដែង សំណងត្រូវបានទូទាត់ដោយពុំមានការពន្យាពេល និងចាត់ចែងឱ្យមានប្រសិទ្ធិភាព ព្រមទាំងត្រូវទូទាត់ដោយរូបិយប័ណ្ណដែលអាចផ្ទេរ និងប្ដូរបានដោយសេរី។

## មាត្រា ៥
## សំណងចំពោះការខាតបង់

១- នៅពេលដែលការវិនិយោគ ឬទិន្នផលនៃការវិនិយោគ របស់ភាគីជាប់កិច្ចសន្យាណាមួយទទួលរងនូវការខាតបង់ដោយសារសង្គ្រាម ជម្លោះអាវុធ ឬស្ថានភាពប្រទេសជាតិមានអាសន្ន ការបះបោរ ភាពចលាចល ឬព្រឹត្តិការណ៍ប្រហាក់ប្រហែលគ្នាដទៃទៀត នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ការខាតបង់នោះ ត្រូវតែទទួលបានការអនុញ្ញាតឱ្យដោយភាគីម្ចាស់ផ្ទះ នូវប្រព្រឹត្តិកម្ម ចំពោះសំណងជាការជួសជុល ការសងសំណង ឬដំណោះស្រាយផ្សេងទៀត ដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះបានអនុញ្ញាតឱ្យ ចំពោះអ្នកវិនិយោគរបស់ខ្លួន ឬ

ចំពោះអ្នកវិនិយោគនៃតតីយរដ្ឋណាមួយនោះឡើយ ពោលគឺប្រព្រឹត្តិកម្មមួយណាដែលមានភាពអនុគ្រោះជាងគេ។

២- ដោយមិនប៉ះពាល់ដល់វាក្យខ័ណ្ឌទី ១ នៃមាត្រានេះ អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ដែលស្ថិតនៅក្នុងហេតុការណ៍ណាមួយនៃវាក្យខ័ណ្ឌនេះ ហើយបានទទួលរងការខាតបង់នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយបណ្តាលមកពី :

ក- ការរឹបអូសនូវការវិនិយោគរបស់ខ្លួនទាំងអស់ ឬមួយផ្នែកនៃការវិនិយោគ ដោយ កម្លាំងទ័ព ឬដោយអាជ្ញាធរ

ខ- ការបំផ្លាញនូវការវិនិយោគទាំងអស់ ឬមួយផ្នែកនៃការវិនិយោគ ដោយកម្លាំងទ័ព ឬអាជ្ញាធរ ដែលមិនមែនបណ្តាលមកពីការប្រយុទ្ធគ្នា ឬតម្រូវឱ្យមាននៅក្នុងស្ថានភាពដែលចាំបាច់នោះ។ ត្រូវទទួលបានពីភាគីជាប់កិច្ចសន្យាដែលការបាត់បង់កើតមាននៅក្នុងទឹកដីរបស់ខ្លួន នោះនូវការជួសជុលឱ្យដូចដើមវិញ ឬសំណងឱ្យបានគ្រប់គ្រាន់ និងមានប្រសិទ្ធិភាព។

សំណងត្រូវរួមបញ្ចូលនូវការប្រាក់តាមអត្រាពាណិជ្ជកម្មសមស្រប ចាប់គិតពីថ្ងៃដែលការខាតបង់បានកើតឡើងរហូតដល់ថ្ងៃទូទាត់។

## មាត្រា ៦
## ការផ្ទេរ

១- ភាគីជាប់កិច្ចសន្យាត្រូវអនុញ្ញាតនូវការផ្ទេរដោយសេរី សម្រាប់ការទូទាត់សំណងទាក់ទងនឹងការវិនិយោគ និងទិន្នផល។ ការផ្ទេរត្រូវធ្វើឡើងដោយរូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី និងស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា ទីដែលការវិនិយោគបានកើតមាន ដោយពុំមានការដាក់កំហិត និងការពន្យាពេលគ្មានកំណត់នោះទេ។ ការផ្ទេរដូចនេះ រួមបញ្ចូលជាអាទិ៍:

ក- មូលធន និងទឹកប្រាក់បន្ថែមសម្រាប់ថែទាំ ឬបង្កើនការវិនិយោគ

ខ- ទិន្នផលដូចបានផ្តល់និយមន័យក្នុងវាក្យខណ្ឌ ៣ នៃមាត្រា ១ នៃកិច្ចព្រមព្រៀងនេះ

គ- ទឹកប្រាក់ដែលត្រូវការ សម្រាប់ការទូទាត់ចំណាយដែលកើតឡើងដោយសារកិច្ចប្រតិបត្តិការនៃការវិនិយោគ ដូចជាការចំណាយទៅលើថ្លៃឈ្នួល ឬកម្រៃអាជ្ញាប័ណ្ណ ឬការចំណាយប្រហាក់ប្រហែលផ្សេងៗទៀត

ឃ- ការចំណាយពាក់ព័ន្ធទៅនឹងកិច្ចសន្យា រួមបញ្ចូលកិច្ចព្រមព្រៀងផ្តល់ប្រាក់កម្ចី

ង- ទ្រព្យសម្បត្តិទាំងអស់ ឬមួយចំណែកដែលបានមកពីការលក់ ឬការជម្រះបញ្ជីវិនិយោគ

ច- ប្រាក់បៀវត្ស ឬចំណូលប្រហាក់ប្រហែលផ្សេងៗទៀតរបស់រូបវ័ន្តបុគ្គល ដែលធ្វើការនៅក្រៅប្រទេស ទាក់ទងទៅនឹងការវិនិយោគ ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិ នៃភាគីជាប់កិច្ចសន្យាដែលការវិនិយោគត្រូវបានដំណើរការ

ឆ- ប្រាក់ប៉ះប៉ូវដែលត្រូវទទួលបាន ដោយអនុលោមទៅតាមមាត្រា ៤ និង ៥ នៃកិច្ចព្រមព្រៀងនេះ

ជ- ការទូទាត់ដែលកើតឡើងពីការដោះស្រាយជម្លោះ តាមមាត្រា ៨ នៃកិច្ចព្រមព្រៀងនេះ។

២- ការផ្ទេរត្រូវបានអនុវត្តក្រោយពេលអ្នកវិនិយោគ បានបំពេញនូវរាល់កាតព្វកិច្ចហិរញ្ញវត្ថុពាក់ព័ន្ធ ស្របតាមច្បាប់ជាធរមាននៃភាគីជាប់កិច្ចសន្យានៅក្នុងទឹកដីដែលបានធ្វើការវិនិយោគ ។

៣- សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ អត្រាប្តូរប្រាក់គឺជាអត្រាដែលបានផ្សព្វផ្សាយស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា ដែលបានទទួលស្គាល់ឱ្យវិនិយោគ ដោយស្ថាប័នហិរញ្ញវត្ថុ ដែលទទួលបន្ទុកការផ្ទេរ លើកលែងតែពុំមានការឯកភាពគ្នាក្រៅពីនេះទេនោះ ។ ប្រសិនបើអត្រានេះពុំមានកំណត់ទេ អត្រាជាផ្លូវការត្រូវបានយកមកអនុវត្ត លើកលែងតែពុំមានការឯកភាពគ្នាក្រៅពីនេះទេនោះ ។

## មាត្រា ៧
## ឧបាទេសកម្ម

១- ប្រសិនបើភាគីជាប់កិច្ចសន្យាម្ខាង ឬភ្នាក់ងារដែលខ្លួនបានតែងតាំងសម្រាប់ទូទាត់ទៅឱ្យអ្នកវិនិយោគរបស់ខ្លួន ក្រោមការធានា ឬកិច្ចធានារ៉ាប់រង ដែលបានអនុញ្ញាតចំពោះការវិនិយោគ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ភាគីម្ចាស់ផ្ទះត្រូវទទួលស្គាល់:

ក- ការផ្ទេរនូវសិទ្ធិអំណាច ឬការទាមទាររបស់អ្នកវិនិយោគ ស្របតាមច្បាប់ ឬអនុលោមតាមការធ្វើពាណិជ្ជកម្មស្របច្បាប់ នៅក្នុងប្រទេសនោះ ដូចភាគីជាប់កិច្ចសន្យា ដែលបានផ្ទេរ ឬភ្នាក់ងារដែលបានទទួលការចាត់តាំងផងដែរ។

ខ- ថាភាគីជាប់កិច្ចសន្យា របស់អ្នកវិនិយោគ ឬភ្នាក់ងាររបស់ភាគីនេះមានសិទ្ធិដោយផ្អែកតាមការធ្វើឧបាទេសកម្ម ដើម្បីអនុវត្តនូវសិទ្ធិអំណាច និងការទាមទារនៃអ្នកវិនិយោគនោះ ហើយក៏ទទួលខុសត្រូវចំពោះកាតព្វកិច្ចដែលទាក់ទងទៅនឹងការវិនិយោគផងដែរ។

២- ឧបាទេសកម្មនូវសិទ្ធិអំណាច និងការទាមទារមិនត្រូវហួសពីសិទ្ធិ និងអំណាចនៃអ្នកវិនិយោគ ដែលបានទទួលពីដំបូងនោះឡើយ ។

## មាត្រា ៨
## ដំណោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

១- វិវាទណាមួយដែលកើតឡើងរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយភាគីជាប់កិច្ចសន្យាម្ខាងទៀត ទាក់ទងទៅនឹងការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះ ត្រូវធ្វើការដោះស្រាយដោយមិត្តភាពតាមរយៈការចរចាររវាងភាគីមានវិវាទ។

២- ការចរចារចាប់ផ្តើមនាថ្ងៃដែលអ្នកវិនិយោគមានវិវាទនៃភាគីជាប់កិច្ចសន្យាម្ខាង លើកសំណើសុំឱ្យមានការចរចារតាមការជូនដំណឹងជាលាយលក្ខណ៍អក្សពី ភាគីជាប់កិច្ចសន្យាម្ខាងទៀត។ ក្នុងស្មារតីសម្រួលដល់ការដោះស្រាយនូវវិវាទជាលក្ខណៈមិត្តភាព ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវធ្វើការបញ្ជាក់អំពីបញ្ហាដែលកើតឡើង មូលដ្ឋានជាដើមចមនៃវិវាទ លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិនិយោគមានវិវាទ (រួមបញ្ចូលទាំងឯកសារគាំទ្រ) និងការសន្និដ្ឋានផ្អែកច្បាប់របស់ខ្លួន។ ល្គឹកណាពុំមានការព្រមព្រៀងក្រៅពីនេះទេនោះ យ៉ាងតិចណាស់ការពិគ្រោះយោបល់មួយ ត្រូវបានធ្វើឡើងក្នុងរយៈពេលកៅសិបថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកវិនិយោគមានវិវាទនៃភាគីជាប់កិច្ចសន្យាបានលើកសំណើសុំចរចារជាលាយលក្ខណ៍អក្សរពីភាគីជាប់កិច្ចសន្យាម្ខាងទៀត។

៣- ប្រសិនបើវិវាទដូចនេះរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាមួយ និងភាគីជាប់កិច្ចសន្យាម្ខាងទៀត ពុំអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ ក្រោយថ្ងៃដែលការចរចារ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរ អ្នកវិនិយោគមានសិទ្ធិបញ្ជូនករណីវិវាទទៅអង្គភាពណាមួយ :

ក- តុលាការមានសមត្ថកិច្ចនៃភាគីជាប់កិច្ចសន្យា ក្នុងទឹកដីដែលការវិនិយោគបានធ្វើឡើង ឬ

ខ- មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ (ICSID) ដែលបង្កើតឡើងសម្រាប់អនុវត្តតាមបញ្ញត្តិនៃអនុសញ្ញា ស្តីពីដំណោះស្រាយវិវាទរវាងរដ្ឋ និងជនជាតិនៃរដ្ឋនានា ដែលបានបើកចំហរការចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៥ ក្នុងករណីដែលភាគីជាប់កិច្ចសន្យាទាំងពីរជាភាគីនៃអនុសញ្ញានេះ ឬ

គ- តុលាការអាជ្ញាកណ្តាលអាដហុក បង្កើតឡើងក្រោមវិធានអាជ្ញាកណ្តាលនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL)។ ភាគីនៃវិវាទ អាចយល់ព្រមជាលាយលក្ខណ៍អក្សរក្នុងការកែសម្រួលវិធានទាំងនោះ ឬ

ឃ- តាមវិធានគ្រប់គ្រងបន្ថែមសម្រាប់នីតិវិធីរដ្ឋបាលរៀបចំដោយលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ (វិធានបន្ថែមនៃ ICSID) ក្នុងករណីភាគីជាប់កិច្ចសន្យាមានវិវាទណាមួយនៃភាគីជាប់កិច្ច

សន្យានៃអ្នកវិនិយោគ ប៉ុន្តែមិនមែនទាំងពីរទេ ជាភាគីនៃអនុសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋដទៃទៀត ដែលបានចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៥ ឬ

ង- ទម្រង់ផ្សេងៗទៀតនៃការដោះស្រាយវិវាទដែលបានយល់ព្រមដោយភាគីមានវិវាទ។

៤- ប្រសិនបើវិវាទរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង និងភាគីជាប់កិច្ចសន្យាម្ខាងទៀតពុំអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីថ្ងៃដែលការចរចារត្រូវបានស្នើឡើង តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដូចមានកំណត់ក្នុងវាក្យខ័ណ្ឌ ២ នៃមាត្រានេះ ហើយអ្នកវិនិយោគមានវិវាទមានបំណងបញ្ជូនករណីវិវាទទៅអង្គការណាមួយដែលមានក្នុងបញ្ជីតាមវាក្យខណ្ឌ ៣ ក-ង អ្នកវិនិយោគមានវិវាទអាចក្នុងពេលចុងក្រោយបំផុត ត្រូវបញ្ជូនករណីវិវាទទៅតុលាការណាមួយ ទន្ទឹមគ្នានឹង ការជូនដំណឹងជាលាយលក្ខណ៍អក្សរនូវបំណងរបស់ខ្លួនទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៥- ក្រោយពេលដែលវិវាទត្រូវបានដាក់ជូនតុលាការណាមួយ ដូចមានកំណត់ក្នុងវាក្យខ័ណ្ឌ ៣ ក-ង អ្នកវិនិយោគមិនអាចស្វែងរកការសុំការដោះស្រាយវិវាទនៅកន្លែងផ្សេងទៀតដែលមានក្នុងបញ្ជីនៃវាក្យខ័ណ្ឌ ៣ ក-ង នោះឡើយ។

៦- អ្នកវិនិយោគអាចបញ្ជូនករណីវិវាទដូចបានយោងតែក្នុងវាក្យខ័ណ្ឌ ១ និង ២ ទៅអាជ្ញាកណ្តាល ស្របតាមវាក្យខណ្ឌ ៣ រយៈពេលមិនលើសពីបីឆ្នាំប៉ុណ្ណោះ ចាប់គិតពីថ្ងៃដែលអ្នកវិនិយោគទទួលបានដំបូង ឬគួរតែទទួលបានដំបូង នូវព័ត៌មានស្តីពីការចោទប្រកាន់បទល្មើស ឬព័ត៌មានដែលអ្នកវិនិយោគនោះ រងការខាតបង់ ឬការខូចខាត។

៧- សេចក្តីសម្រេចត្រូវតែជាសេចក្តីសម្រេចចុងក្រោយ និងត្រូវបានអនុវត្តដោយភាគីមានវិវាទ ព្រមទាំងត្រូវអនុវត្តស្របទៅតាមច្បាប់នៃភាគីជាប់កិច្ចសន្យានៅក្នុងទឹកដី ដែល

បានធ្វើការវិនិយោគ ហើយសេចក្ដីសម្រេចមានសុពលភាពអនុវត្តចាប់គិតពីថ្ងៃដែលបានកំណត់នៅក្នុងសេចក្ដីសម្រេច ។

## មាត្រា ៩
## ដំណោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាពាក់ព័ន្ធការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ ប្រសិនបើអាចធ្វើបាន ត្រូវដោះស្រាយតាមរយៈការទូត តាមការពិគ្រោះយោបល់ ឬការចរចារ ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ និងនៅពេលមានសំណើពីភាគីណាមួយ វិវាទនោះត្រូវដាក់ជូនទៅតុលាការអាជ្ញាកណ្ដាលដែលមានសមាជិកបីរូប ស្របទៅតាមបញ្ញត្តិនៃមាត្រានេះ។

៣- តុលាការអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងទៅតាមករណីដោយឡែកៗតាមរបៀប ដូចតទៅៈ ក្នុងរយៈពេលពីរខែ ចាប់គិតពីថ្ងៃទទួលបានពាក្យបណ្ដឹង ភាគីជាប់កិច្ចសន្យានីមួយៗត្រូវតែងតាំងសមាជិករបស់ខ្លួនមួយរូបនៅក្នុងតុលាការ។ សមាជិកទាំងពីររូបនោះ ត្រូវជ្រើសរើសជនជាតិនៃតតីយរដ្ឋមួយរូប ដែលត្រូវតែងតាំងជាប្រធានតុលាការ (ចាប់ពីពេលនេះតទៅហៅថា "ប្រធាន") ។ ប្រធានត្រូវបានតែងតាំងក្នុងរយៈពេលពីរខែ ចាប់គិតពីថ្ងៃ ដែលបានតែងតាំងសមាជិកទាំងពីររូប។

៤- ប្រសិនបើក្នុងអំឡុងពេលដែលបានបញ្ជាក់ក្នុងវាក្យខ័ណ្ឌ ៣ នៃមាត្រានេះតម្រូវការចាំបាច់នៃការតែងតាំងមិនអាចដោះស្រាយបាន សំណើសុំតែងតាំងអាចដាក់ជូនប្រធានតុលាការយុត្តិធម៌អន្តរជាតិដើម្បីទទួលការតែងតាំង ។ ប្រសិនបើប្រធានតុលាការដែលបានតែងតាំងនោះ ជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបានដោយប្រការណាមួយនោះ អនុប្រធានតុលាការត្រូវបានអញ្ជើញឱ្យធ្វើជាប្រធាន ។ ប្រសិន បើអនុប្រធានក៏ជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារខាងលើនេះបានទៀតនោះ សមាជិកនៃតុលាការយុត្តិធម៌

អន្តរជាតិ ដែលមានឋានៈបន្ទាប់ និងមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ត្រូវបានអញ្ជើញឱ្យធ្វើជាប្រធាន។

៥- តុលាការអាជ្ញាកណ្ដាលត្រូវធ្វើការសម្រេចរបស់ខ្លួនដោយបោះឆ្នោតយកសំឡេងភាគច្រើន ។

៦- តុលាការត្រូវចេញសេចក្ដីសម្រេចរបស់ខ្លួនលើមូលដ្ឋាននៃការគោរពច្បាប់ បទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាការគោរពគោលការណ៍នៃច្បាប់អន្តរជាតិផងដែរ។

៧- ពាក់ព័ន្ធទៅនឹងបណ្ដាបទប្បញ្ញត្តិផ្សេងៗដែលធ្វើឡើងដោយភាគីជាប់កិច្ចសន្យា តុលាការត្រូវកំណត់ចេញនូវនីតិវិធីរបស់ខ្លួន ។

៨- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវទទួលរ៉ាប់រងនូវការចំណាយសម្រាប់អាជ្ញាកណ្ដាល និងអ្នកតំណាងរបស់ខ្លួននៅក្នុងដំណើរការនៃការកាត់ក្ដីរបស់អាជ្ញាកណ្ដាល។ ការចំណាយសម្រាប់ប្រធាន និងចំណាយផ្សេងៗទៀតគឺជាបន្ទុកដែលភាគីជាប់កិច្ចសន្យាទាំងពីរត្រូវទទួលរ៉ាប់រងស្មើគ្នា។ តុលាការអាជ្ញាកណ្ដាលអាចធ្វើបទប្បញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការចំណាយ។

៩- សេចក្ដីសម្រេចរបស់តុលាការគឺជាសេចក្ដីសម្រេចចុងក្រោយ និងត្រូវទទួលអនុវត្តដោយភាគីជាប់កិច្ចសន្យាទាំងពីរ។

## មាត្រា ១០
## ការអនុវត្តវិធានផ្សេងៗទៀត និងការសន្យាពិសេស

ពុំមានខ្លឹមសារអ្វីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់ដើម្បីរឹតត្បិតនូវសិទ្ធិរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យា ក្នុងការទទួលបាននូវផលប្រយោជន៍ពីប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះបំផុតនៅក្នុងកិច្ចព្រមព្រៀងទ្វេរភាគី ឬពហុភាគីនាពេលបច្ចុប្បន្ន ឬនាពេលអនាគតដែលខ្លួនជាភាគីនោះឡើយ។

## មាត្រា ១១
## វិសាលភាពនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះការវិនិយោគដែលធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន នៅមុនក៏ដូចជានៅក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនអនុវត្តចំពោះវិវាទ ឬការតវ៉ាណាមួយពាក់ព័ន្ធការវិនិយោគដែលបានកើតឡើង ឬបានដោះស្រាយរួចហើយនៅមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះទេ ។

## មាត្រា ១២
## ការពិគ្រោះយោបល់

នៅពេលមានសំណើពិគ្រោះយោបល់ភាគីជាប់កិច្ចសន្យាណាមួយ ភាគីជាប់កិច្ចសន្យាម្ខាងទៀតត្រូវយល់ព្រមទទួលយកការពិគ្រោះយោបល់ស្តីពីការបកស្រាយ ឬ ការអនុវត្តកិច្ចព្រមព្រៀងនេះ ។ នៅពេលមានសំណើពីភាគីជាប់កិច្ចសន្យាម្ខាងព័ត៌មានស្តីពីផលប៉ះពាល់ច្បាប់ បទប្បញ្ញត្តិ សេចក្តីសម្រេច ការអនុវត្ត ឬនីតិវិធីរដ្ឋបាល ឬគោលនយោបាយរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលអាចមានក្នុងការវិនិយោគក្រោមកិច្ចព្រមព្រៀងនេះ ត្រូវតែផ្តល់ឱ្យគ្នាទៅវិញទៅមក។

## មាត្រា ១៣
## ការលើកលែងទូទៅ

១- ពុំមានខ្លឹមសារអ្វីក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីរារាំងភាគីជាប់កិច្ចសន្យាក្នុងការដាក់ឱ្យប្រើ ឬរក្សាទុកនូវវិធានការសមស្របសម្រាប់ហេតុផលប្រុងប្រយ័ត្ននោះឡើយ ដូចជា :

ក- ការថែទាំសុវត្ថិភាព ភាពរឹងមាំ បូរណភាព ឬការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់ស្ថាប័នហិរញ្ញវត្ថុ និង

ខ- ការធានានូវបូរណភាព និងស្ថេរភាពនៃប្រព័ន្ធហិរញ្ញវត្ថុរបស់ភាគីជាប់កិច្ចសន្យា ។

២- ក- ពុំមានខ្លឹមសារអ្វីក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយ ដើម្បីរារាំងភាគីជាប់កិច្ចសន្យាមួយក្នុងការដាក់ឱ្យប្រើ ឬរក្សាទុកនូវវិធានការដែលដាក់កំហិតលើការផ្ទេរប្រាក់ក្នុងពេលដែលភាគីជាប់កិច្ចសន្យា ទទួលរងនូវការលំបាកធ្ងន់ធ្ងរនៃជញ្ជីងទូទាត់ ឬរងការគំរាមកំហែងនៃជញ្ជីងទូទាត់នោះឡើយ។ ការដាក់កំហិតត្រូវធ្វើឡើងដោយមានសង្គតិភាពទៅនឹងកថាខ័ណ្ឌ ខ

ខ- វិធានការដាក់កំហិតដូចយោងនៅក្នុងកថាខ័ណ្ឌ ក ត្រូវធ្វើដោយយុត្តិធម៌ មិនមានការរំលោភបំពាន ឬរើសអើងដោយអយុត្តិធម៌ មានភាពសុចរិតទៀងត្រង់នៅក្នុងរយៈពេលកំណត់មួយ និងពុំអាចធ្វើឱ្យហួសពីអ្វីដែលត្រូវធ្វើដើម្បីស្តារស្ថានភាពនៃជញ្ជីងទូទាត់នោះឡើយ។ ភាគីជាប់កិច្ចសន្យាដែលបានដាក់ចេញនូវវិធានការតាមមាត្រានេះ ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតជាបន្ទាន់ ដោយបង្ហាញកម្មវិធីនៃពេលវេលាដែលត្រូវដកចេញវិញនូវការប្រើប្រាស់វិធានការដាក់កំហិតនោះ នៅពេលឆាប់ៗតាមដែលអាចធ្វើទៅបានផង។ វិធានទាំងនោះ ត្រូវប្រកាន់យកដោយអនុលោមទៅតាមកាតព្វកិច្ចអន្តរជាតិផ្សេងទៀតនៃភាគីជាប់កិច្ចសន្យាដែលពាក់ព័ន្ធ រួមបញ្ចូលទាំងកាតព្វកិច្ចទាំងឡាយនៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក និងបណ្តាមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

៣- ពុំមានខ្លឹមសារអ្វីក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយៈ

ក- ដើម្បីរារាំងភាគីជាប់កិច្ចសន្យាណាមួយក្នុងការធ្វើសកម្មភាព ដែលចាត់ទុកថា ជាការចាំបាច់ដើម្បីការពារនូវផលប្រយោជន៍សន្តិសុខជាសារវ័ន្តរបស់ខ្លួន

(i) ទាក់ទងទៅនឹងការរត់ពន្ធអាវុធ គ្រាប់រំសេវ សម្ភារៈសឹក និងការធ្វើសកម្មភាពជំនួញផ្សេងៗទៀត ជាទំនិញ សម្ភារៈបរិក្ខារ សេវាកម្ម និងបច្ចេកវិទ្យា ដែលអនុវត្តដោយផ្ទាល់ ឬដោយប្រយោលក្នុងគោលបំណងធ្វើការផ្គត់ផ្គង់ដល់មូលដ្ឋានទ័ព ឬសន្តិសុខនានា

(ii) ដែលបានធ្វើឡើងក្នុងពេលមានសង្គ្រាម ឬក្នុងពេលមានភាពអាសន្នផ្សេងទៀតនៅក្នុងកិច្ចទំនាក់ទំនងអន្តរជាតិ ឬ

(iii) ទាក់ទងទៅនឹងការអនុវត្តន៍គោលនយោបាយជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិស្តីពី ការមិនសាយភាយអាវុធនុយក្លេអ៊ែរ ឬឧបករណ៍បំផ្ទុះនុយក្លេអ៊ែរដ៏ទៃទៀត ឬ

ខ- ដើម្បីរារាំងភាគីជាប់កិច្ចសន្យាណាមួយក្នុងការធ្វើសកម្មភាព ដោយអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមធម្មនុញ្ញសហប្រជាជាតិស្តីពីការថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

៤- ភាគីជាប់កិច្ចសន្យាអាចបដិសេធការទទួលបាននូវផលចំណេញពីកិច្ចព្រមព្រៀងនេះ ចំពោះអ្នកវិនិយោគណាមួយនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលជានីតិបុគ្គល និងចំពោះការវិនិយោគរបស់អ្នកវិនិយោគនោះ ក្នុងករណីដែលអ្នកវិនិយោគនៃរដ្ឋទី៣ ធ្វើជាម្ចាស់ ឬគ្រប់គ្រងលើអ្នកវិនិយោគ ដែលបានបញ្ជាក់ពីខាងដើមហើយៈ

ក- អ្នកវិនិយោគនោះ ពុំមានកិច្ចការធុរកិច្ចជាដុំកំភួននៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យា ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ឬ

ខ- ភាគីជាប់កិច្ចសន្យាដែលជាអ្នកបដិសេធបានដាក់ឱ្យប្រើ ឬរក្សាទុកនូវវិធានការទាំងឡាយចំពោះរដ្ឋទី៣ ដែលហាមឃាត់ការធ្វើសកម្មភាពជំនួញជាមួយអ្នកវិនិយោគដូចនេះ និងការវិនិយោគរបស់គេ ឬថាភាគីនោះអាចត្រូវបានបំពាន ឬត្រូវបានពង្វាង ប្រសិនបើផលប្រយោជន៍នៃកិច្ចព្រមព្រៀងត្រូវបានផ្តល់ចំពោះការវិនិយោគនៃអ្នកវិនិយោគទាំងនោះ ។

៥- ផលប្រយោជន៍សន្តិសុខជាសារវ័ន្តរបស់ភាគីជាប់កិច្ចសន្យា អាចរួមបញ្ចូលនូវផលប្រយោជន៍ និងវិធានការដែលបានមកពីភាពជាសមាជិកនៅក្នុងសហភាពគយ សេដ្ឋកិច្ច ឬសហគមន៍រូបិយវត្ថុទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរី។

៦- រាល់ឯកសារយោងក្នុងកិច្ចព្រមព្រៀង ពាក់ព័ន្ធទៅនឹងរាល់វិធានការនៃភាគីជាប់កិច្ចសន្យាមួយ នឹងរួមបញ្ចូលផងដែរ នូវរាល់វិធានការអនុវត្តស្របតាមច្បាប់របស់ EU នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ដោយអនុលោមតាមភាពជាសមាជិករបស់ខ្លួននៅក្នុងសភាពអឺរ៉ុប។ ឯកសារយោងពាក់ព័ន្ធទៅនឹងការលំបាកធ្ងន់ធ្ងរនៃជញ្ជីងទូទាត់ ឬការគំរាមកំហែងនៃជញ្ជីងទូទាត់នោះ នឹងមានការរួមបញ្ចូលផងដែរ នូវការលំបាកធ្ងន់ធ្ងរនៃជញ្ជីងទូទាត់ ឬការគំរាមកំហែងនៃជញ្ជីងទូទាត់ ក្នុងសហភាពសេដ្ឋកិច្ច ឬសហគមន៍រូបិយវត្ថុ ដែលភាគីជាប់កិច្ចសន្យាមួយជាសមាជិក។

៧- ការដោះស្រាយវិវាទ ដែលអនុលោមទៅតាមមាត្រា ៨ ពុំត្រូវបានចាត់ទុកដូចជាប្រព្រឹត្តិកម្ម ភាពអនុគ្រោះ ឬបុព្វសិទ្ធិនោះទេ។

## មាត្រា ១៤
## អវសានប្បញ្ញត្តិ ការចូលជាធរមាន រយៈពេល ការបញ្ចប់ និងការធ្វើវិសោធនកម្ម

១- កិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តដោយពុំធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចដែលកើតមានពីភាពជាសមាជិកនៃសហភាពអឺរ៉ុបនោះឡើយ និងអនុលោមទៅតាមកាតព្វកិច្ចទាំងនោះ។ ដូចនេះ បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះពុំអាចយកមកប្រើ ឬធ្វើការបកស្រាយទោះបីទាំងស្រុង ឬមួយផ្នែកក្តី ដើម្បីមោឃភាពកែប្រែ ឬប៉ះពាល់ដល់កាតព្វកិច្ចហុងគ្រី ដែលមានចែងក្នុង សន្ធិសញ្ញារបស់សហភាពអឺរ៉ុប ក៏ដូចជាមានចែងក្នុងច្បាប់ជាមូលដ្ឋាន ឬច្បាប់បន្ទាប់បន្សំនៃសហភាពអឺរ៉ុបនោះបានឡើយ។

២- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈពេលសាមសិបថ្ងៃ ក្រោយថ្ងៃទទួលបាននូវសេចក្តីជូនដំណឹងចុងក្រោយនៃសេចក្តីជូនដំណឹងទាំងពីរដែលត្រូវបានបញ្ជូនតាមផ្លូវទូតដែលភាគីជាប់កិច្ចសន្យាម្ខាង ជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតថារាល់តម្រូវការផ្នែកច្បាប់ក្នុងស្រុក សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងត្រូវបានបំពេញរួចរាល់ហើយ ។

៣- កិច្ចព្រមព្រៀងនេះមានសុពលភាព សម្រាប់រយៈពេលដប់ឆ្នាំ ហើយបន្តមានសុពលភាពជាបន្ត លើកលែងតែភាគីជាប់កិច្ចសន្យាម្ខាង បានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតជាលាយលក្ខណ៍អក្សរ អំពីការបញ្ចប់កិច្ចព្រមព្រៀងនៅក្នុងរយៈពេលយ៉ាងតិចណាស់មួយឆ្នាំ មុនពេលផុតសុពលភាព នៃរយៈពេលដប់ឆ្នាំដំបូង ឬពេលណាមួយបន្ទាប់ពីនោះ។ កិច្ចព្រមព្រៀង នឹងបញ្ចប់រយៈពេលដប់ពីរខែ ចាប់គិតពីថ្ងៃដែលភាគីជាប់កិច្ចសន្យាណាមួយបានផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរពីការបញ្ចប់ទៅឱ្យភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៤- បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះត្រូវបន្តមានសុពលភាពអនុវត្ត សម្រាប់រយៈពេលដប់ឆ្នាំទៀត ចាប់គិតពីថ្ងៃបញ្ចប់។ ចំពោះការវិនិយោគទាំងឡាយណាបានធ្វើមុនពេលកិច្ចព្រមព្រៀងនេះ ត្រូវបានបញ្ចប់។

៥- កិច្ចព្រមព្រៀងនេះ អាចធ្វើវិសោធនកម្មតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីជាប់កិច្ចសន្យា។ ការធ្វើវិសោធនកម្មណាមួយដែលជាផ្នែកមួយភ្ជាប់ទៅនឹងកិច្ចព្រមព្រៀង និងចូលជាធរមានតាមនីតិវិធីដូចគ្នាដែលតម្រូវសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងដែលមាននេះដែរ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធអំណាចគ្រប់គ្រាន់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅភ្នំពេញថ្ងៃទី ១៤. ខែ មករា. ឆ្នាំ២០១៦ ជាភាសាខ្មែរ ភាសាហុងគ្រី និងភាសាអង់គ្លេស ដោយអត្ថបទទាំងអស់នេះមានតម្លៃស្មើៗគ្នាតាមផ្លូវច្បាប់។ ក្នុងករណីមានការបកស្រាយមិនស្របគ្នា នោះអត្ថបទជាភាសាអង់គ្លេស ត្រូវបានយកមកធ្វើជាសំអាង ។

**តំណាងរដ្ឋាភិបាល**
**នៃព្រះរាជាណាចក្រកម្ពុជា**

..............................................

**តំណាងរដ្ឋាភិបាល**
**ហុងគ្រី**

..............................................